រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :

Project WorldReach PWR ™

474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

049KH01A-01

ចូរយើងឃ្វាល



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

៤៩

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ផ្នែក ទី ១

គុណសម្បត្តិរបស់គ្រូគង្វាល

ទូលសូមអោយព្រះជាម្ចាស់ជួយអ្នក អោយអាចបំពេញកិច្ចការ
ឃ្វាលបានល្អប្រសើរ ។

នៅក្នុងព្រះគម្ពីរ គេហៅគ្រូគង្វាលថា÷ «ព្រឹទ្ធាចារ្យ » ឬ«អ្នក
ទទួលខុសត្រូវក្នុងក្រុមជំនុំ » (១ ពេត្រុស ៥:១-៤) ឬ«អ្នក
គង្វាល » (អេភេសូ ៤:១១-១២) ឬ «អ្នកដឹកនាំក្រុមជំនុំ »
ឬ«អ្នកអភិបាល » (ទីតុស ១:៥-៧, ១ ធីម៉ូថេ ៣:១) ។

ពាក្យសំរាប់ហៅគ្រូគង្វាលទាំងនេះ បញ្ជាក់អំពីកិច្ចការតែមួយ គឺ
កិច្ចការឃ្វាល ។ ក្រុមជំនុំដែលមានការរៀបចំល្អ ត្រូវមានគ្រូ
គង្វាលជំនួយ ឬ អ្នកចាស់ទុំច្រើននាក់សហការជាមួយគ្នា
(ទីតុស ១:៥) ។

ដើម្បីអាចក្លាយជាគ្រូគង្វាលបាន ដំបូង យើងត្រូវរៀបចំជីវិតខាង
ព្រលឹងវិញ្ញាណរបស់យើងផ្ទាល់សិន ។ ក្នុងចំណោមសេចក្តី នៅ
ទំព័របន្ទាប់នេះ ដែលដកស្រង់ពី ១ ធីម៉ូថេ ចំពូក ៣ សូមគូស
សញ្ញា «✓»នេះ នៅខាងស្តាំគុណសម្បត្តិនីមួយៗ ដែលអ្នកត្រូវ
ធ្វើអោយរីកចំរើនឡើង នៅក្នុងជីវិតរបស់អ្នក :

(សូមពន្យល់ដោយប្រើខគម្ពីរ រ៉ូម ១២:៤-៨, ១ កូរិនថូស
ជំពូក ១២ និង អេភេសូ ៤:១១-១២) ។

- រក្សាទុកឯកសារ កំណត់ត្រា និង ក្រដាសស្នាមរបស់អ្នក
ក្នុងទូរមួយ ដោយដាក់តាមលំដាប់តួអក្សរ ។ អ្នកអាចទុក
ឯកសារនេះក្នុងកេះក្រដាស ដោយដាក់បន្ទះក្រដាសកាតុង
ខ័ណ្ឌផ្នែកនិមួយៗ ។ ឧទាហរណ៍ ការសិក្សាអំពីការអធិស្ឋាន
ត្រូវដាក់ក្នុងលំដាប់អក្សរ «អ » ។ គំរោងអំពីការគ្រប់គ្រង
ថវិកា ត្រូវដាក់ក្នុងលំដាប់អក្សរ «ថ » ។

កំណត់ចំណាំ :

© Project WorldReach © SEAN

ភារៈកិច្ចរបស់ក្រុមជំនុំចំពោះគ្រូគង្វាល

- ធ្វើតាមគំរូរបស់គ្រូគង្វាល (១ កូរិនថូស ១១:១) ។
- ស្តាប់តាមគ្រូគង្វាល (ហេប្រឺ ១៣:១៧) ។
- អធិស្ឋានសំរាប់គ្រូគង្វាល (ហេប្រឺ ១៣:១៨) ។
- ឧបត្ថម្ភគ្រូគង្វាល (១ ធីម៉ូថេ ៥:១៧-១៨) ។

កិច្ចការដែលត្រូវអនុវត្ត

- អាន ធីម៉ូថេ ទី ១ ទាំងមូល ។ សរសេរភារៈកិច្ចទាំងប៉ុន្មាន របស់គ្រូគង្វាល ដែលលោកប៉ូលបានបង្រៀននៅក្នុងសំបុត្រ នេះ ។
- បង្រៀនអំពីខ្លឹមសាររបស់ការសិក្សានេះ ដល់អ្នកដែលចូល រួមបំពេញកិច្ចការឃ្វាលនៅក្នុងក្រុមជំនុំ ឬ ក្រុមរបស់អ្នក ។
- រៀបចំពួកអ្នកចាស់ទុំ និង សមាជិកទាំងអស់របស់ក្រុមជំនុំ អ្នក អោយបំពេញភារៈកិច្ចរបស់ខ្លួន ស្របទៅតាមអំណោយ ទានរបស់ខ្លួន ។

- ☐ គុណសម្បត្តិល្អឥតខ្ចោះ (ខ ២) ។
- ☐ មានភរិយាតែមួយ (ខ ២) ។
- ☐ មានចិត្តធ្ងន់ (ចេះទប់ចិត្ត និង ចេះអប់រំចិត្តក្នុងគ្រប់កាល: ទេស:) (ខ ២)
- ☐ មានកិរិយាមារយាទល្អ (ខ ២) ។
- ☐ ចេះទទួលភ្ញៀវ (ខ ២) ។
- ☐ ចេះបង្រៀន (មានសមត្ថភាពខាងការប្រាស្រ័យទាក់ទង ជាមួយអ្នកដទៃ) (ខ ២) ។
- ☐ មិនស្រវឹងស្រា និង មិនចំណូលស្រា (ខ ២-៣) ។
- ☐ មិនចេះឈ្លោះប្រកែក គឺមានចិត្តសប្បុរស (ខ ៣) ។
- ☐ មិនចេះរករឿង (ចេះកសាងសន្តិភាព និង មានអធ្យាស្រ័យ) (ខ ៣) ។
- ☐ មិនស្រឡាញ់ប្រាក់ (ខ ៣) ។

© Project WorldReach © SEAN

☐ ចេះមើលខុសត្រូវលើក្រុមគ្រួសាររបស់ខ្លួនផ្ទាល់ ព្រមទាំងអោយកូនចៅរបស់ខ្លួនចេះស្តាប់បង្គាប់ និង មានកិរិយាថ្លៃថ្នូរទាំងស្រុង (ខ ៤-៥) ។

☐ មិនមែនជាអ្នកទើបនឹងជឿ (ខ ៦) ។

☐ មិនចេះអួតបំប៉ោង (មិនត្រូវមានឫកក្រអឺត) (ខ ៦) ។

☐ មានកេរ្តិ៍ឈ្មោះល្អពីសំណាក់អស់អ្នកដែលមិនមែនជាគ្រីស្តបរិស័ទ (ខ ៧) ។

កិច្ចការឃ្វាលខាងការផ្តល់ដំបូន្មាន

- ធ្វើកិច្ចការឃ្វាលខាងផ្តល់ដំបូន្មានដល់ពួកអ្នក ដែលមានបញ្ហាផ្ទាល់ខ្លួន ។

  អ្នកទទួលខុសត្រូវ : _____

- ផ្តល់ដំបូន្មានដល់សមាជិក ដែលធ្លាក់ទឹកចិត្ត ។

  អ្នកទទួលខុសត្រូវ : _____

- ផ្តល់ដំបូន្មានដល់ប្តីប្រពន្ធ និង គ្រួសារ ដែលជិតរៀបការ ។

  អ្នកទទួលខុសត្រូវ : _____

- ជួយគ្រួសារទាំងឡាយរបស់អ្នកជឿកនាំ អោយរួមសហការជាមួយគ្នា ក្នុងការបំពេញមុខងារបំរើរបស់ពួកគេ ។

  អ្នកទទួលខុសត្រូវ : _____

© Project WorldReach © SEAN

គុណសម្បត្តិល្អឥតខ្ចោះ

គ្រូគង្វាលត្រូវមានគំនិត និង ឥរិយាបថល្អបរិសុទ្ធ ព្រោះគាត់ជាគំរូ អំពីព្រះគ្រីស្តសំរាប់មនុស្សទូទៅ ។ ដើម្បីអាចរស់នៅ ដោយមាន គុណសម្បត្តិល្អឥតខ្ចោះបាន យើងត្រូវសូមទោសពួកអ្នក ដែលយើង បានធ្វើខុសឆ្គងទៅលើ នៅក្នុងសហគមន៍ ។ ម៉្យាងទៀត យើង ត្រូវដើរដោយពឹងលើព្រះវិញ្ញាណដ៏វិសុទ្ធ គឺត្រូវអធិស្ឋាន និង រិះ គិតពិចារណាពីព្រះបន្ទូលព្រះជាម្ចាស់ ព្រមទាំងអនុវត្តតាមព្រះ-បន្ទូលព្រះជាម្ចាស់ផងដែរ ។ បើសិនជាអ្នកមិនសូវអធិស្ឋាន អ្នក នឹងមិនសូវមានឫទ្ធានុភាពខាងព្រលឹងវិញ្ញាណទេ ។ ការអធិស្ឋាន នាំឱ្យយើងបានជាប់ជាមួយព្រះជាម្ចាស់ ហើយទទួលឫទ្ធានុភាព ពីទ្រង់ ប្រៀបដូចជាខ្សែភ្លើងអគ្គីសនី ដែលនាំថាមពលពីប្រភព របស់វា ទៅកន្លែងដែលយើងបើកភ្លើងដែរ ។



បើសិនជាយើងមិនអនុវត្តតាមអ្វីដែលយើងអធិប្បាយ តើមនុស្ស នឹងគោរពយើងដែរឬទេ ? ។ _____

- ការសិក្សាព្រះគម្ពីរសំរាប់មនុស្សពេញវ័យ ។

  អ្នកទទួលខុសត្រូវ : _____

- ការសិក្សាព្រះគម្ពីរសំរាប់ក្រុមគ្រួសារទាំងមូល ។

  សេចក្តីសំខាន់ : យើងមិនត្រូវអោយនិស្សិតដែលមានអាយុ ផ្សេងគ្នា សិក្សាក្នុងក្រុមតែមួយជាមួយគ្នាទេ ។ បើមិន ដូច្នេះទេ និស្សិតនឹងពិបាកទាក់ទងគ្នា និង មិនអាចយល់ មេរៀនបានពេញលេញ ។ សូមខិតខំបង្កើតក្រុមដែលមាន សមាជិកជាមនុស្សអាយុស្របាល(ប្រហែល)គ្នា និង មាន តួនាទីប្រហែលគ្នាក្នុងគ្រួសារ ។

  អ្នកទទួលខុសត្រូវ : _____

មានភរិយាតែមួយ

គ្រូគង្វាលត្រូវមានមេត្រីភាពជាប់ជានិច្ច ជាមួយភរិយារបស់ខ្លួន ។ គាត់មិនត្រូវសម្លឹងរកស្ត្រីផ្សេងទៀតទេ ។ *«ចូរគេចចេញអោយផុតពីតណ្ហានៃយុវវ័យ »* (២ ធីម៉ូថេ ២:២២) ។ ស្ត្រីដែលក្បត់ប្តីប្រៀបបាននឹងផ្លូវ ដែលតំរង់ទៅរកមច្ចុរាជ (សុភាសិត ៥:៣-៥)។

បើសិនជាអ្នកដឹងខ្លួនថា មានចិត្តទៅលើស្ត្រីផ្សេងហើយ តើអ្នកត្រូវធ្វើដូចម្តេច ? ។

_____

_____

_____

_____

_____

_____

- លើកទឹកចិត្តកុមារ និង យុវជនអោយមានសេចក្តីស្រឡាញ់ និង ចេះគោរពចាស់ទុំ ហើយបង្រៀនអំពីទំនាក់ទំនងរវាងស្វាមីភរិយា និង រវាងឪពុកម្តាយ និង កូន ។

  អ្នកទទួលខុសត្រូវ : _____

- ការសិក្សាព្រះគម្ពីរសំរាប់កុមារតូចៗ ។

  អ្នកទទួលខុសត្រូវ : _____

- ការសិក្សាព្រះគម្ពីរសំរាប់កុមារតូចៗល្មម ។

  អ្នកទទួលខុសត្រូវ : _____

- ការសិក្សាព្រះគម្ពីរសំរាប់កុមារធំៗ ។

  អ្នកទទួលខុសត្រូវ : _____

- ការសិក្សាព្រះគម្ពីរសំរាប់យុវជន ។

  អ្នកទទួលខុសត្រូវ : _____

© Project WorldReach © SEAN

ការបង្ហាត់បង្រៀនគ្រីស្តជន

- រៀបចំធ្វើកម្មវិធីសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល គ្រីស្តទូត និង អ្នកដឹកនាំ ។

  អ្នកទទួលខុសត្រូវ : _____

- ណែនាំប្រមូលពួកអ្នកដឹកនាំថ្មី ស្របទៅតាមសេចក្តីត្រូវការ ។ (ជួបជាមួយពួកគេដោយទៀងទាត់ ហើយពិភាក្សាគ្នាអំពីការងារ ដែលពួកគេត្រូវធ្វើ) ។

  អ្នកទទួលខុសត្រូវ : _____

- បង្រៀនពួកអ្នកដឹកនាំថ្មីថែមទៀត អំពីគោលជំនឿរបស់ក្រុមជំនុំ និង វិធីទាំងឡាយរបស់ក្រុមជំនុំ ។

  អ្នកទទួលខុសត្រូវ : _____

- បង្ហាត់បង្រៀនពួកអ្នកដឹកនាំក្រុមតូចតាមផ្ទះ ។

  អ្នកទទួលខុសត្រូវ : _____

មានចិត្តធ្ងន់

(ចេះទប់ចិត្ត/ចេះអប់រំចិត្តក្នុងគ្រប់កាលៈទេសៈ)

គ្រូគង្វាល**ត្រូវចេះទប់ចិត្ត** ។ បានន័យថា គាត់មិនត្រូវធ្វើអ្វីដែលបំពេញតែចិត្តគាត់នោះទេ (កាឡាទី ៦:៧-៨) គឺគាត់ត្រូវប្រតិបត្តិតាមព្រះបន្ទូលព្រះជាម្ចាស់វិញ ។ *«តើមនុស្សកំលោះត្រូវធ្វើយ៉ាងណា ដើម្បីឱ្យកិរិយាមារយាទរបស់ខ្លួនបានល្អត្រឹមត្រូវ ? គឺដោយប្រតិបត្តិតាមព្រះបន្ទូលរបស់ព្រះអង្គ... ។ សូមកុំបណ្តោយអោយទូលបង្គំងាកចេញពីវិន័យរបស់ព្រះអង្គឡើយ »* (ទំនុកតម្កើង ១១៩:៩-១០) ។ ដូចនេះ ដើម្បីអោយគ្រូគង្វាលអាចមានជីវិតបរិសុទ្ធ គាត់ត្រូវចេះគ្រប់គ្រងចិត្តគំនិត ពាក្យសំដី អាកប្បកិរិយា និង ការប្រព្រឹត្តរបស់គាត់ (កាឡាទី ៥:១៦) ។

លើសពីនេះទៅទៀត គ្រូគង្វាលត្រូវចេះស្កប់ចិត្ត ។ លោកប៉ូលជាមនុស្សដែលចេះស្កប់ចិត្តក្នុងគ្រប់កាលៈទេសៈ ។ គាត់មិនមែនជាមនុស្សដែលគិតតែពីស៊ីផឹកសប្បាយ និង ប្រមូលទ្រព្យសម្បត្តិទេ ផ្ទុយទៅវិញ គាត់ទទួលស្គាល់ថា មានតែការរួមជាមួយព្រះអម្ចាស់យេស៊ូប៉ុណ្ណោះ ដែលធ្វើអោយគាត់ស្កប់ចិត្ត (ភីលីព ៣:១៩-២០, ៤:១១-១៣) ។

គ្រូគង្វាលដែលចេះអប់រំខ្លួន អាចចាត់ចែងការងារឃ្វាលរបស់គាត់ ប្រកបដោយប្រសិទ្ធិភាព ។ គាត់មិនមែនជាមនុស្សខ្ជិលច្រអូសទេ តែជាមនុស្សឧស្សាហ៍ព្យាយាមធ្វើការងារ ។ គាត់អធិស្ឋានមុន នឹងផ្តល់ដំបូន្មាន ហើយការពារក្រុមជំនុំគាត់ពីគោលជំនឿក្លែងក្លាយ ។ គាត់ចេះរបៀបថែរក្សាសុខភាពរបស់គាត់ និង បង្រៀនគ្រួសារគាត់អំពីអនាម័យ ដើម្បីអោយគ្រួសារគាត់មានសុខភាពល្អទាំងអស់គ្នាដែរ ។

បើសិនជាគ្រូគង្វាលជាមនុស្សខ្ជិល មិនចេះស្តប់ចិត្ត ឆាប់ខឹង ចេះភរ ឬ ចេះគ្នួញតែរ ។ល។ តើសេចក្តីអធិប្បាយ និង ការបង្រៀនរបស់គាត់មានប្រសិទ្ធិភាពដែរឬទេ ? ។ _____

មានកិរិយាមារយាទល្អ

គ្រូគង្វាលដែលមានកិរិយាមារយាទល្អ ទាក់ទាញមនុស្សទៅរកដំណឹងល្អរបស់ព្រះយេស៊ូ ។ ដោយសារតែគាត់មានការប្រព្រឹត្តបរិសុទ្ធ ព្រះវិញ្ញាណដ៏វិសុទ្ធអាចធ្វើកិច្ចការតាមរយៈគាត់ ។ គាត់មិនដែលមានអំពើបាបលាក់កំបាំងក្នុងចិត្ត និង ក្នុងជីវិតរបស់គាត់ទេ ។ គាត់ប្រព្រឹត្តនៅក្នុងក្រុមជំនុំ និង នៅក្នុងក្រុមគ្រួសារដូចគ្នា គឺថា គាត់គ្មានមុខមាត់ពីរទេ ។ គាត់មិនដែលគោរពព្រះជាម្ចាស់តែបបូរមាត់ ឯចិត្តឆ្ងាយពីព្រះជាម្ចាស់នោះទេ (ម៉ាថាយ ១៥:៨) ។

- ជ្រើសយកចំរៀងសរសើរតម្កើង ដែលត្រូវនឹងប្រធានបទ (ជ្រើសរើសចំរៀងដែលនាំឱ្យសមាជិកទាំងអស់ច្រៀងដោយអស់ពីចិត្ត) ។
- ប្រាប់ពតិមាននេះដល់ពួកអ្នកច្រៀង អ្នកភ្លេង និង អ្នកដឹកនាំចំរៀងអោយបានមុន ។
- រៀបចំសំរាប់ធ្វើពិធីកាច់នំប៉័ង ។
- រៀបចំការសំដែងឆាកល្ខោនស្តីអំពីព្រះបន្ទូលព្រះជាម្ចាស់ ។ល។ និង ដែលទាក់ទងនឹងការអធិប្បាយផងដែរ ។

អ្នកទទួលខុសត្រូវ : _____

ការថ្វាយបង្គំ

- កំណត់ប្រធានបទរបស់ពិធីថ្វាយបង្គំនិមួយៗ សំរាប់មួយឆ្នាំ (តាមរយៈគោលជំនឿព្រះគម្ពីរ គោលការណ៍ផ្សេងៗរបស់សៀវភៅនិមួយៗនៃព្រះគម្ពីរ និង សេចក្តីត្រូវការបច្ចុប្បន្នរបស់សមាជិកក្រុមជំនុំ) ។

  អ្នកទទួលខុសត្រូវ : _____

- ផ្តល់ពតិមាន មុនពេលកំណត់ ដល់ពួកអ្នកដែលត្រូវចូលរួមដឹកនាំការថ្វាយបង្គំ ។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំសំរាប់កម្មវិធីពិសេសៗ ។

  អ្នកទទួលខុសត្រូវ : _____

- ណែនាំអ្នកដឹកនាំការថ្វាយបង្គំអោយ :

  - រៀបគំរោងរបៀបវារៈនៃពិធីថ្វាយបង្គំ (ការអានព្រះ-គម្ពីរ ការច្រៀងសរសើរ ។ល។ ស្របទៅតាមប្រធានបទ និង កាលៈទេសៈ) ។

គោលដៅរបស់គាត់ គឺពិតជាផ្សព្វផ្សាយដំណឹងល្អដល់ពួកអ្នកដែលលិចលង់ ក្នុងអំពើបាប មិនមែនលួចចៀមពីក្រុមជំនុំផ្សេងទៀតទេ ។ គាត់គ្មានចិត្តចង់ប្រកួតប្រជែងជាមួយគ្រូគង្វាល ឬ ក្រុមជំនុំផ្សេងទេ ។ គាត់មិនចេះនិយាយភរ ដើម្បីអោយបានប្រាក់ ឬ សំភារៈសំរាប់ក្រុមជំនុំរបស់គាត់នោះទេ ។ បំណងគាត់មានមូលហេតុបរិសុទ្ធ ហើយមនៈសិការរបស់គាត់ក៏ជ្រះថ្លាដែរ (២ កូរិនថូស ១:១២) ។

តើអ្នកប្រព្រឹត្តជាមួយក្រុមគ្រួសារ និង មិត្តភ័ក្តិរបស់អ្នក ដូចអ្នកប្រព្រឹត្តជាមួយក្រុមជំនុំដែរឬទេ ? ។ _____



© Project WorldReach © SEAN

ចេះទទួលភ្ញៀវ

តួនាទីរបស់គ្រូគង្វាល និង គ្រួសាររបស់គាត់ គឺទទួលភ្ញៀវ ដោយរាក់ទាក់ និង ដោយសេចក្តីស្រឡាញ់ ។ គ្រូគង្វាលដែលចេះទទួលភ្ញៀវ ជាគ្រូគង្វាលដែលចេះអធិស្ឋានជាមួយភ្ញៀវរបស់គាត់ និងលើកទឹកចិត្តពួកគេដោយពាក្យសំដី និង សកម្មភាព ។ គ្រូគង្វាលត្រូវចេះអត់ធ្មត់ និង ចេះចំណាយពេលសមរម្យជាមួយភ្ញៀវរបស់គាត់ ។

ជួនកាលមានមនុស្សមកជួបនឹងគ្រូគង្វាល ដើម្បីសុំអោយគាត់ជួយម្តងហើយម្តងទៀត តែមិនខិតខំដោះស្រាយបញ្ហាខ្លួនឯងសោះ ។ គ្រូគង្វាលមិនត្រូវចំណាយពេលជាមួយមនុស្សបែបនេះទេ ។ ពួកគេគ្រាន់តែបង្ខាតពេលវេលារបស់គ្រូគង្វាលប៉ុណ្ណោះ ។



- ប្រៀនប្រដៅ និង កែតម្រង់អស់អ្នកណាដែលធ្លាក់ចុះក្នុងសេចក្តីល្បួង ។

  អ្នកទទួលខុសត្រូវ : _____

- បង្កើតក្រុមជំនុំសាខា ។

  អ្នកទទួលខុសត្រូវ : _____

- វាយតម្លៃការផ្សាយដំណឹងល្អ ហើយចាប់ផ្តើមផ្សាយដំណឹងល្អតាមរបៀបថ្មី ឬ កែប្រែវិធីផ្សាយដំណឹងល្អ តាមការវាយតំលៃនោះ ។

  អ្នកទទួលខុសត្រូវ : _____

- លើកទឹកចិត្តអោយចាប់អារម្មណ៍ និង ចូលរួមក្នុងបេសកកម្មគ្រីស្តទូត ។

  អ្នកទទួលខុសត្រូវ : _____

- សាកសួរស្ទង់មើលមនុស្ស ដែលចង់ចូលជាសមាជិក (អ្នកដែលមកពីក្រុមជំនុំផ្សេងៗ នៅក្នុងតំបន់ផ្សេងៗទៀត) ។

  អ្នកទទួលខុសត្រូវ : _____

- ធ្វើពិធីជ្រមុជទឹកអោយពួកអ្នកជឿថ្មី ។

  អ្នកទទួលខុសត្រូវ : _____

- បង្រៀនសមាជិកទាំងអស់អោយក្លាយជាសាវ័ក ។

  អ្នកទទួលខុសត្រូវ : _____

- លើកទឹកចិត្តឱ្យសមាជិកទាំងអស់ដាក់ដង្វាយដប់ភាគរយ ដោយអំណរ ។

  អ្នកទទួលខុសត្រូវ : _____

- ណែនាំប្រមូលសមាជិកទាំងអស់ ឱ្យចូលរួមបំពេញមុខងារ បំរើ ។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំក្រុមសំរាប់មុខងារបំរើពិសេសផ្សេងៗ (ការទៅសួរសុខទុក្ខក្នុងមន្ទីរឃុំឃាំង ឬ មន្ទីរពេទ្យ ។ល។) ។

  អ្នកទទួលខុសត្រូវ : _____

ហេតុអ្វីបានជាប្រពន្ធរបស់គ្រូគង្វាល ត្រូវតែស្រុះស្រួលរួមចិត្តគំនិត និង ចូលរួមធ្វើកិច្ចការបំរើជាមួយប្តី ? ។

_____

_____

_____

ចេះបង្រៀន

(មានសមត្ថភាពខាងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ)

អំណោយទានខាងការបង្រៀន រីកចំរើនបន្តិចម្តងៗ ពេលយើងចាប់ផ្តើមផ្សាយដំណឹងល្អពីព្រះយេស៊ូគ្រីស្ត ។ នៅពេលដែលអ្នកមានសមត្ថភាព និង បទពិសោធន៍កាន់តែច្រើនឡើងខាងការបង្រៀន ការបង្រៀនរបស់អ្នកនឹងបង្កើតផលផ្លែច្រើនមុខ ។

គ្រូគង្វាលត្រូវរៀបចំខ្លួនឯងផ្ទាល់ ដោយសិក្សាព្រះគម្ពីរ សិក្សាប្រវត្តិសាស្ត្ររបស់ក្រុមជំនុំ និង សិក្សាពីកិច្ចការឃ្វាល ។

គ្រូគង្វាលត្រូវរៀបចំខ្លួនអោយបានត្រឹមត្រូវ ដើម្បីបង្រៀនអោយបានល្អ ។ គ្រូគង្វាលឈ្លាសវៃ ត្រូវរៀន និង អនុវត្តតាមការសិក្សាពីកិច្ចការឃ្វាលទាំងអស់របស់កម្មវិធី « បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត » នេះ ។

ដើម្បីបង្រៀនឱ្យបានល្អ គ្រូគង្វាលត្រូវមានសេចក្តីភ្លាហាន និង ចេះបន្ទាបខ្លួន ។ មារសាតាំងល្បួងយើងឱ្យចង់បានការសរសើរពីមនុស្ស : « *កុំធ្វើ... ដើម្បីអោយមនុស្សម្នាឃើញនោះឡើយ* » (សុភាសិត ២៩:២៥) ។

យើងត្រូវបង្រៀនពីសេចក្តីពិត ទោះជាមនុស្សឯទៀតគិតយ៉ាងណាក៏ដោយ (ទីតុស ១:៩) ។

បើគ្រូគង្វាលឈប់សិក្សាព្រះបន្ទូល សេចក្តីអធិប្បាយរបស់គាត់នឹងធ្វើអោយគេធុញទ្រាន់ ។ ហេតុអ្វី ? ។

_____

_____

_____

_____

_____

ការផ្សាយដំណឹងល្អ ការបង្កើតសាវ័ក និង បេសកកម្មគ្រីស្តទូត

- រៀបចំការអធិស្ឋាន និង ការតមអាហារ ។ល។...។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំការផ្សាយដំណឹងល្អតាមផ្ទះ ។

  អ្នកទទួលខុសត្រូវ : _____

- ធ្វើកម្មវិធីផ្សាយដំណឹងល្អ និង របៀបផ្សាយដំណឹងល្អផ្សេងៗទៀត ។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំក្រុមតូចថ្មីៗទៀត ។

  អ្នកទទួលខុសត្រូវ : _____

- ជួយសមាជិកម្នាក់ៗ អោយអាចប្រតិបត្តិតាមសេចក្តីបង្គាប់របស់ព្រះគ្រីស្ត ។

  អ្នកទទួលខុសត្រូវ : _____

_____

© Project WorldReach © SEAN

- ចាត់ចែងមុខងារបំរើខាងការថែទាំរបស់របរ (ដី អាគារ ប្រដាប់ប្រដា ។ល។) ។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំសកម្មភាពប្រកបគ្នា ។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំអោយមានការសហការជាមួយគ្រូគង្វាលនៃក្រុមជំនុំផ្សេងៗទៀត ។

  អ្នកទទួលខុសត្រូវ : _____

- ជំរុញអោយពួកអ្នកចាស់ទុំជួយគ្នាទៅវិញទៅមក និង អោយពួកអ្នកដឹកនាំសហការគ្នា ។

  អ្នកទទួលខុសត្រូវ : _____

មិនស្រវឹងស្រា និង មិនចំណូលស្រា

គ្រូគង្វាលល្អ មិនត្រូវប្រមឹកស្រា ឬ មានទម្លាប់អាក្រក់ផ្សេងទៀតនោះឡើយ ។ បើអ្នកផ្សេងទៀតប្រមឹកស្រា ឬ មានទម្លាប់អាក្រក់ផ្សេងទៀត សូមប្រើក្ងនសៀវភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាលទី ៣៩ «ការប្រដៅទូន្មាន ដោយសេចក្តីស្រឡាញ់» របស់កម្មវិធី «បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត» ។

តើយើងត្រូវធ្វើដូចម្តេច ដើម្បីកុំអោយសមាជិករបស់យើងផឹកស្រាស្រវឹងជ្រុល នៅក្នុងពិធីជប់លៀង ? តើក្រុមជំនុំត្រូវរៀបចំការប្រជុំប្រកបគ្នា និង សកម្មភាពសង្គមអ្វីខ្លះ ដើម្បីជំនួសពិធីជប់-លៀងទាំងនោះ ? ។

_____

_____

_____

_____

_____

_____

មិនចេះឈ្លោះប្រកែក គឺមានចិត្តសប្បុរស

លោកយ៉ាកុបសួរថា÷ «ការទាស់ទែង ឈ្លោះប្រកែកគ្នាក្នុងចំណោមបងប្អូន កើតមកពីអ្វី ? » (យ៉ាកុប ៤:១-៣) ។ គ្រូគង្វាលមិនត្រូវបណ្តោយអោយបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់គាត់បណ្តាលអោយកើតមានការឈ្លោះប្រកែកក្នុងក្រុមជំនុំគាត់ទេ ។ គាត់ត្រូវមានចិត្តសប្បុរសវិញ ។ សុភាសិត ១៥:១ ចែងថា÷ *«ចំលើយទន់ភ្លន់ រមែងបន្ថយកំហឹង រីឯសំដីគំរោះគំរើយ តែងតែធ្វើអោយច្រឡោតខឹង »* ។ បានន័យថា មនុស្សអាចបញ្ឈប់ការឈ្លោះប្រកែកបាន ដោយនិយាយពាក្យសំដី ដែលប្រកបដោយសេចក្តីស្រឡាញ់ ឬ ពាក្យសំដីល្អៗ ។ សូមអោយព្រះជាម្ចាស់ជួយអោយអ្នកចេះទប់ចិត្តខ្លួនឯង ដើម្បីអាចបញ្ឈប់ការឈ្លោះប្រកែក មិនមែនបង្កឿងឈ្លោះប្រកែកទេ ។ បើអ្នកមានបញ្ហាដោយសារកំហឹង សូមប្រើក្លូនសៀវភៅសំរាប់បង្ហាត់បង្រៀនកិច្ចការឃ្វាលទី ៥៣ «សកម្មភាពនៃសេចក្តីស្រឡាញ់ » ។

តើអ្នកអាចលើកទឹកចិត្តសមាជិកក្រុមជំនុំរបស់អ្នក ឱ្យចៀសវាងការបែកបាក់គ្នា គីអោយចេះទទួលភ្ញៀវដោយរាក់ទាក់វិញ ដោយរបៀបណា ? _____

_____

_____

- កំណត់កាលបរិច្ឆេទ និង រៀបចំប្រតិទិនសំរាប់ការប្រជុំរបស់គ្រូគង្វាល និង អ្នកដឹកនាំឯទៀត ។

  អ្នកទទួលខុសត្រូវ : _____

- ចាត់ចែងមុខងារបំរើពិសេសផ្នែកបុរស ។

  អ្នកទទួលខុសត្រូវ : _____

- ចាត់ចែងមុខងារបំរើពិសេសផ្នែកស្ត្រី ។

  អ្នកទទួលខុសត្រូវ : _____

- ចាត់ចែងមុខងារបំរើពិសេសផ្នែកយុវជន ។

  អ្នកទទួលខុសត្រូវ : _____

- ចាត់ចែងមុខងារបំរើរបស់ពួកអ្នកជំនួយ (ខាងការងារសង្គមកិច្ច ខាងការជួយអ្នក ដែលមានសេចក្តីត្រូវការ ។ល។) ។

  អ្នកទទួលខុសត្រូវ : _____

ការណែនាំ និង ការចាត់ចែងទូទៅ

- រៀបចំផែនការ ដើម្បីបំពេញភារៈកិច្ច (កំណត់ភារៈកិច្ច និង ចាត់តាំងអ្នកចាត់ចែង ដែលត្រូវទទួលខុសត្រូវ) ។

  អ្នកទទួលខុសត្រូវក្នុងការសំរេចកិច្ចការនេះ : _____

- វាយតំលៃភារៈកិច្ចគ្រប់យ៉ាង (ជួយពួកអ្នកដឹកនាំអោយធ្វើរបាយការណ៍អំពីភារៈកិច្ច ដែលពួកគេទទួលខុសត្រូវ) ។

  អ្នកទទួលខុសត្រូវ : _____

- រៀបចំសម្រួលការងាររបស់លេខា និង ហេរញ្ញិក : (រៀបចំគំរោងថវិកា គ្រប់គ្រងចំណាយ និង ចំណូល រៀបចំឯកសារ ដែលទាក់ទងនឹងហិរញ្ញវត្ថុ ។ល។) ។

  អ្នកទទួលខុសត្រូវ : _____

- កំណត់បទបញ្ជាត្តិទូទៅ ។

  អ្នកទទួលខុសត្រូវ : _____

តើអ្នកធ្វើដូចម្តេច ដើម្បីលើកទឹកចិត្តសមាជិកក្រុមជំនុំអោយមានសេចក្តីស្រឡាញ់កាន់តែខ្លាំង ? _____

_____

មិនចេះរកស៊ើង

(ចេះកសាងសន្តិភាព និង មានអធ្យាស្រ័យ)

មារសាតាំងសាបព្រោះជម្លោះ និង ការបែកបាក់នៅក្នុងក្រុមជំនុំ ។ នៅក្នុងក្រុមជំនុំតែងតែមានមនុស្ស ដែលបង្កអោយមានការបែកបាក់ ដោយនិយាយដើម ទិតៀន (១ ធីម៉ូថេ ៦:៣-៥) ។ រីឯគ្រូគង្វាលវិញ ត្រូវសាបព្រោះសេចក្តីសុខសាន្ត (១ ធីម៉ូថេ ៦:២០, យ៉ាកុប ៣:១៨) ។ ជួនកាលគ្រូគង្វាលខំការពារខ្លួនពីការចោទប្រកាន់ផ្តេសផ្តាស់របស់អ្នកដទៃ ដោយទិតៀនគេវិញ ។ តែសូមនឹកចាំថា បើសិនជាអ្នកត្រូវគេចោទប្រកាន់ផ្តេសផ្តាស់ អ្នកមិនត្រូវសងសឹកទេ ព្រោះបើអ្នកសងសឹក អ្នកនឹងដូចជាអ្នកដែលចោទប្រកាន់អ្នកនោះដែរ ។ អ្នកចាំបាច់ត្រូវចេះអត់ធ្មត់ និងស៊ូទ្រាំខ្លាំងណាស់ ។ ការពិត គ្រូគង្វាលមិនសូវបានទទួលការលើកទឹកចិត្តពីក្រុមជំនុំរបស់គាត់ទេ ។ ទោះជាយ៉ាងណាក៏ដោយ

សូមកុំនឿយណាយនឹងការប្រព្រឹត្តអំពើល្អឡើយ (កាឡាទី ៦:៩) ។ សំខាន់បំផុត អ្នកមិនត្រូវធ្វើកិច្ចការណា ដែលអាចក្លាយជាប្រភពនៃការទាស់គ្នានោះទេ ។

តើអ្នកអាចជួយក្រុមជំនុំអ្នក អោយអាចចៀសផុតពីការរកឿងគ្នាទៅវិញទៅមកបាន ដោយរបៀបណា ?

នៅទំព័របន្ទាប់នេះ សូមសរសេរឈ្មោះអ្នកដែលទទួលខុសត្រូវខាងការត្រួតពិនិត្យលើភារៈកិច្ចនិមួយៗ ។ ការដែលល្អ គឺត្រូវអោយគ្រូគង្វាល ឬ អ្នកចាស់ទុំម្នាក់ទទួលខុសត្រូវលើមុខងារនិមួយៗ ដើម្បីអាចរៀបចំ និង ធ្វើអោយមុខងារបំរើទាំងឡាយដំណើរការល្អ និង អ្នកបំពេញមុខងារបំរើទាំងអស់ស្រុះស្រួលគ្នា ។ នៅក្នុងបញ្ជីនោះ សូមបន្ថែមភារៈកិច្ចផ្សេងៗទៀត ដែលក្រុមជំនុំអ្នកត្រូវបំពេញ ។ បញ្ជីនេះចែកជាផ្នែកផ្សេងៗដែលមាន : ការចាត់ចែងការផ្សាយដំណឹងល្អ ការបង្កើតសាវ័ក បេសកកម្មគ្រីស្តទូត ការថ្វាយបង្គំ ការបង្ហាត់បង្រៀនគ្រីស្តជន និង កិច្ចការឃ្វាលខាងផ្តល់ជំបូន្មាន ។

© Project WorldReach © SEAN

ផ្នែក ទី ៣

ចាត់តាំងអោយអ្នកចាស់ទុំបំពេញភារៈកិច្ចឃ្វាល

នៅក្នុងក្រុមជំនុំក្នុងសម្ពន្ធមេត្រីថ្មី អ្នកចាស់ទុំ (គ្រូគង្វាល) ច្រើននាក់បំពេញភារកិច្ចឃ្វាលរួមជាមួយគ្នា ។ ដើម្បីអោយគ្រូគង្វាល និង អ្នកចាស់ទុំជាច្រើន អាចចូលរួមបំពេញមុខងារបំរើខាងការឃ្វាលបាន ត្រូវកំណត់ភារៈកិច្ចផ្សេងៗសំរាប់ម្នាក់ៗ ។ ការចាត់តាំងមុខងារបំរើមួយអោយគ្រូគង្វាល ឬ អ្នកចាស់ទុំណាម្នាក់បំពេញមិនមែនបានន័យថា គាត់ត្រូវបំពេញមុខងារបំរើនោះតែម្នាក់ឯងទេ គឺបានន័យថា គាត់ទទួលខុសត្រូវធ្វើមុខងារបំរើនោះអោយបានសំរេច (ដោយខ្លួនគាត់ផ្ទាល់ ឬ ដោយមនុស្សទាំងឡាយដែលគាត់អោយបំពេញមុខងារបំរើនោះ) ។ គ្រូគង្វាល ឬ អ្នកចាស់ទុំ គឺជាអ្នកគ្រប់គ្រង ឬ អ្នកត្រួតពិនិត្យកិច្ចការឃ្វាល យោងទៅតាម អេភេសូ ៤:១១-១២, ១ ធីម៉ូថេ ៣:១-៧, និង ទីតុស ១:៥-៧ ។

មិនស្រឡាញ់ប្រាក់

មនុស្សខ្លះថ្វាយខ្លួនជាគ្រីស្តជន និង ជាគ្រូគង្វាលដើម្បីរកប្រាក់ ។ ពួកគេរកឃើញរបៀបប្រើប្រាស់ក្រុមជំនុំ ដើម្បីអោយបានផលប្រយោជន៍ផ្ទាល់ខ្លួន ។ មនុស្សខ្លះទៅព្រះវិហារ ព្រោះពួកគេចង់បានប្រាក់ ឬ អំណោយពីក្រុមជំនុំ ។

មនុស្សខ្លះទៀតចង់មានទំនាក់ទំនងជាមួយនឹងក្រុមជំនុំ ដើម្បីបានការងារធ្វើ ។ គ្រូគង្វាលទាំងឡាយ សូមមេត្តាកុំធ្វើជាមនុស្សដែលសាកល្បងក្លែងបន្លំព្រះជាម្ចាស់ ដោយប្រើប្រាស់ឋានៈរបស់អ្នក ដើម្បីទទួលលុយពីសាសនទូត ឬ ប្រើប្រាស់ថវិការបស់ក្រុមជំនុំ ដោយមិនត្រឹមត្រូវអោយសោះ (ទីតុស ១:៧) ។ ប្រាក់ជាប្រភពនៃសេចក្តីអាក្រក់គ្រប់យ៉ាង ដូច្នេះ សូមការពារខ្លួនអ្នកពីការល្បួងខាងលុយកាក់ (១ ធីម៉ូថេ ៦:៥-១១, ១៧-១៩) ។

© Project WorldReach © SEAN

គ្រូគង្វាលខ្លះអធិប្បាយដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ។ គ្រូគង្វាលខ្លះទាមទារអោយក្រុមជំនុំថ្វាយដង្វាយច្រើនថែមទៀត តែពួកគេផ្ទាល់មិនថ្វាយ ដោយចិត្តសប្បុរសទេ ។ តើអ្នកមានគំនិតដូចម្តេចដែរ ? ។ _____

តើមារសាតាំងមានបំណងយ៉ាងណា ដែលក្តែងបន្លំខ្លួនវាធ្វើជាគ្រូ-បង្រៀនសេចក្តីពិតដូចនេះ ? ។

© Project WorldReach © SEAN

គ្រូគង្វាលដែលចេះប្រតិបត្តិតាមព្រះគ្រីស្ត ត្រូវតែជួយមនុស្សដែលមានសេចក្តីត្រូវការ ។ គ្រូគង្វាលត្រូវទៅសួរសុខទុក្ខអ្នក ដែលធ្លាក់ទឹកចិត្ត និង មានជំងឺ (ឬ ប្រាប់អោយអ្នកជំនួយរបស់ក្រុមជំនុំជួយធ្វើកិច្ចការនេះ) ។

ត្រូវស្វាគមន៍ភ្ញៀវដែលមកក្រុមជំនុំរបស់អ្នក ។ បន្ទាប់មក ទៅសួរសុខទុក្ខភ្ញៀវទាំងនោះដល់ផ្ទះ ដើម្បីនិយាយប្រាប់ពួកគេអំពីព្រះយេស៊ូគ្រីស្ត ។

គ្រូគង្វាលត្រូវតែប្រុងប្រយ័ត្ន ពេលដែលមាន «ឆ្កែចចក» ចូលមកក្នុងក្រុមជំនុំ ឬ ក្រុមតូច (ម៉ាថាយ ៧:១៥-២០) ។ មារសាតាំងមិនដែលបង្ហាញខ្លួនជាឆ្កែចចកទេ តែវាក្លែងបន្លំធ្វើជាទេវតានៃពន្លឺវិញ (២ កូរិនថូស ១១:១៤) ។ ឆ្កែចចកទាំងនោះក្លែងខ្លួនពាក់ស្បែកចៀម ។ ពួកគេអួតខ្លួនថា ពួកគេវិសុទ្ធ ហើយនិយាយតែពីសាសនា ។ ត្រូវដាស់តឿនប្រាប់ក្រុមជំនុំរបស់អ្នកអំពីគ្រូក្លែងក្លាយ ។ ត្រូវបង្រៀនក្រុមជំនុំអោយចេះមើលស្គាល់ និង បដិសេធ «ពួកឆ្កែចចក» ។ កុំអនុញ្ញាតិអោយគ្រូបង្រៀនដែលអ្នកមិនស្គាល់ មកទាក់ទងបង្រៀនសមាជិករបស់ក្រុមជំនុំរបស់អ្នក ។





ខ្ញុំឈប់ធ្វើជាគ្រូគង្វាលនៅក្នុងក្រុមជំនុំនេះហើយ ។ ខ្ញុំទៅបំរើព្រះអង្គក្នុងក្រុមជំនុំណា ដែលទិញម៉ូតូអោយគ្រូគង្វាលវិញ ។

ត្រូវធ្វើជាមនុស្ស ដែលមានចិត្តសប្បុរស គួរជាទីទុកចិត្ត និង ស្មោះត្រង់ (លូកា ១៦:១០) ។ អ្នករាល់គ្នាបានទទួល ដោយឥតបង់ថ្លៃ សូមជួយគេវិញ ដោយឥតគិតថ្លៃដែរ (ម៉ាថាយ ១០:៨, ២ កូរិនថូស ៩:៦-១០) ។

គ្រួគង្វាលត្រូវធ្វើជាគំរូល្អក្នុងការធ្វើអំណោយ និង ការដាក់ដង្វាយជប់ភាគរយ ។ បើអ្នកដឹកនាំមិនថ្វាយដង្វាយជប់ភាគរយ និងដង្វាយស្ម័គ្រចិត្តទេ នោះក្រុមជំនុំរបស់គាត់នឹងមិនថ្វាយ ដូចគាត់ដែរ ។ គ្រួគង្វាលមិនត្រូវធ្វើជាហេរញ្ញិករបស់ក្រុមជំនុំគាត់ទេ ។ ហេតុអ្វីបានជាសមាជិកមិនគោរពគ្រួគង្វាល ដែលគិតតែពីសំភារៈខាងសាច់ឈាម ? ។ _____

_____

ចេះមើលខុសត្រូវលើក្រុមគ្រួសាររបស់ខ្លួនផ្ទាល់ ព្រមទាំងអោយកូនចៅរបស់ខ្លួនចេះស្តាប់បង្គាប់ និង មានកិរិយាថ្លៃថ្នូរទាំងស្រុង

គ្រួគង្វាលដែលមិនចេះថែរក្សាក្រុមគ្រួសាររបស់គាត់ អោយមានសណ្តាប់ធ្នាប់ មិនមានជំយជំនះក្នុងការថែរក្សាក្រុមជំនុំទេ ។ គ្រួគង្វាល និង គូស្រករបស់គាត់ ត្រូវស្រឡាញ់គ្នាទៅវិញទៅមក ហើយប្រៀនប្រដៅកូនៗរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ ។ គ្រួគង្វាល និង ក្រុមគ្រួសាររបស់គាត់ ត្រូវធ្វើជាគំរូល្អសំរាប់ក្រុមគ្រួសារទាំងអស់ក្នុងក្រុមជំនុំ ។

មើលថែហ្វូងចៀម និង សួរសុខទុក្ខសមាជិក ដើម្បីស្គាល់ពួកគេ ព្រមទាំងជួយពួកគេនៅពេលដែលពួកគេមានសេចក្តីត្រូវការ ហើយដឹកនាំពួកគេអោយអាចបំពេញកិច្ចការបំរើ

«...សូមបងប្អូនថែរក្សាខ្លួនឯង និង ថែរក្សាក្រុមអ្នកជឿទាំងមូលផង ព្រោះព្រះវិញ្ញាណដ៏វិសុទ្ធបានផ្ទុកផ្តាក់អោយបងប្អូន ធ្វើជាអ្នកទទួលខុសត្រូវនេះ ដើម្បីអោយបងប្អូនថែរក្សាក្រុមជំនុំ / ព្រះ-សហគមន៍របស់ព្រះជាម្ចាស់ ដែលព្រះអង្គបានលោះមក ដោយសារព្រះលោហិតរបស់ព្រះអង្គផ្ទាល់ » ។

(កិច្ចការ ២០:២៨)



© Project WorldReach © SEAN

☐ ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។

☐ សារៈសំខាន់នៃពិធីកាច់នំបុ័ង ។

☐ សកម្មភាពចាំបាច់របស់ក្រុមជំនុំ (អធិស្ឋាន ផ្សាយដំណឹងល្អ ធ្វើពិធីជ្រមុជទឹក បង្កើតក្រុមជំនុំថ្មី ចាត់សាសនទូត ព្រមទាំងថែរក្សាមនុស្សចាស់ អ្នកជំងឺ ស្ត្រីមេម៉ាយ និង ក្មេងកំព្រា ។ល។) ។

☐ ភារៈកិច្ចរបស់គ្រីស្តជនជាប្តី ប្រពន្ធ កូន ឪពុកម្តាយ និងជាពលរដ្ឋ ។ល។ ...។

គ្រូអធិប្បាយដែលខ្ជិល តែងតែអធិប្បាយសេចក្តីដដែលៗ ហើយមិនដែលផ្លាស់ប្តូរប្រធានបទនៃសេចក្តីអធិប្បាយរបស់គាត់ទេ ។ បើធ្វើដូចនេះ ក្រុមជំនុំនឹងខ្វះអាហារខាងព្រលឹងវិញ្ញាណ ។

តើគ្រូគង្វាលត្រូវធ្វើដូចម្តេច ដើម្បីជ្រើសរើសប្រធានបទនៃសេចក្តីអធិប្បាយ ដោយឈ្លាសវៃ ? ។

សមាជិកមិនគោរពគ្រូគង្វាល ដែលមិនគិតអំពីក្រុមគ្រួសារ និងជីវភាពក្រុមគ្រួសាររបស់គាត់នោះទេ ។



© Project WorldReach © SEAN

តើអ្នកអាចថែរក្សាគ្រួសាររបស់អ្នកអោយប្រសើរបាន ដោយរបៀបណា ? ។

_____

_____

_____

_____

_____

_____

_____

ដើម្បីនឹងទទួលការសង្គ្រោះ ដោយមានជំនឿលើព្រះយេស៊ូគ្រីស្ត ។ គ្រប់អត្ថបទគម្ពីរ សុទ្ធតែព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណមកបំភ្លឺ ដើម្បីតែង និង មានប្រយោជន៍សំរាប់បង្រៀនរកខុសត្រូវ កែតម្រង់ និង អប់រំអោយរស់តាមសេចក្តីសុចរិត ក្នុងគោលបំណងអោយអ្នកបំរើរបស់ព្រះជាម្ចាស់មានសមត្ថភាព និង ប្រុងប្រៀបខ្លួនជាស្រេចដើម្បីប្រព្រឹត្តអំពើល្អគ្រប់ជំពូក » ។

តើអ្នកសិក្សាព្រះគម្ពីរ ដោយទៀងទាត់ដែរឬទេ ? (សូមគូសសញ្ញា «✓» នេះ នៅនឹងគោលជំនឿដែលអ្នកត្រូវបង្រៀនថែមទៀត) ។

☐ លក្ខណៈសម្បត្តិរបស់ព្រះជាម្ចាស់តែមួយគត់ ។

☐ បុគ្គល និង កិច្ចការរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ។

☐ បុគ្គល និង កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ ។

☐ ភារៈកិច្ចនៃការបង្កើតសាវ័ករបស់ព្រះគ្រីស្ត ។

☐ អំពើបាប និង លទ្ធផលនៃអំពើបាប ។

☐ ការកែប្រែចិត្តគំនិត ជំនឿ និង ការកើតជាថ្មី ។

☐ ភាពបរិសុទ្ធ ។

© Project WorldReach © SEAN

មិនមែនជាអ្នកទើបនឹងជឿ

ក្រុមជំនុំត្រូវអធិស្ឋានជាក់ដៃតែងតាំងគ្រូគង្វាលថ្មី នៅពេលដែលគ្រូគង្វាលនោះបង្ហាញថា គាត់មានអំណោយទានជាគ្រូគង្វាលដោយសារផលផ្លែ ដែលគាត់បង្កើត ដូចជា :

- មានចរិតលក្ខណៈបរិសុទ្ធ ។
- នាំមនុស្សអោយថ្វាយខ្លួន ។
- មានសេចក្តីស្រឡាញ់ចំពោះក្រុមជំនុំ ។
- មានភាពចាស់ទុំខាងព្រលឹងវិញ្ញាណ ។ល។ ។



បង្រៀន

«រីឯអ្នកបំរើរបស់ព្រះអម្ចាស់... ត្រូវចេះបង្រៀន... » ។

(២ ធីម៉ូថេ ២:២៤)

គ្រូគង្វាលដែលប្រតិបត្តិតាមព្រះគ្រីស្ត ត្រូវចេះបង្រៀនព្រះគម្ពីរដល់ក្រុមជំនុំទាំងមូល និង តាមផ្ទះ (កិច្ចការ ៥:៤២, ២០:២០) លើសពីនេះទៅទៀត គ្រូគង្វាលត្រូវចេះបង្ហាត់បង្រៀន «ធីម៉ូថេ» ទាំងអស់របស់គាត់ គឺអ្នកសិក្សាដែលចេះសង្កេតមើល និង ធ្វើតាមគ្រូបង្ហាត់របស់ខ្លួន (២ ធីម៉ូថេ ២:១-២) ។

គ្រូគង្វាលមិនត្រូវបង្រៀនតាមរបៀបគ្រូបង្រៀនសិស្ស នៅតាមសាលារៀនទេ ។ គាត់មិនមែនឈរនៅពីមុខសិស្ស ហើយនិយាយរហូតនោះទេ តែគាត់ត្រូវបង្រៀនអ្នកសិក្សា ដោយធ្វើជាគំរូសំរាប់ពួកគេវិញ (ទីតុស ២:៧-៨, ១ ពេត្រុស ៥:៣) ។

ព្រះគម្ពីរជាឧបករណ៍ ជាអាវុធ និង ជាដាវរបស់គ្រូអធិប្បាយ ។ យើងចាំបាច់ ត្រូវចេះចែកផ្សាយព្រះបន្ទូលអោយបានត្រឹមត្រូវ (២ ធីម៉ូថេ ២:១៥) ។ សាវ័កប៉ូលនិយាយប្រាប់លោកធីម៉ូថេ នៅក្នុង ២ ធីម៉ូថេ ៣:១៥-១៧ ថា÷ *«អ្នកស្គាល់ព្រះគម្ពីរតាំងតែពីនៅកុមារម្ល៉េះ ហើយព្រះគម្ពីរអាចផ្តល់អោយអ្នកមានប្រាជ្ញា*

ជំបួង អ្នកដែលចង់ធ្វើជាគ្រូគង្វាល ត្រូវបង្ហាញអោយឃើញថា គាត់រីកចំរើនឡើងជាចាស់ទុំខាងព្រលឹងវិញ្ញាណ និង មានចរិត-លក្ខណៈជាគ្រីស្តជនសិន ។ ១ ធីម៉ូថេ ៥:២២ ទូន្មានថា÷ «*កុំប្រញាប់ដាក់ដៃតែងតាំងអ្នកណាម្នាក់ពេក* » ។

ពួកអ្នកចាស់ទុំត្រូវអធិស្ឋានដាក់ដៃលើអ្នក ដែលមានសមត្ថភាពធ្វើជាគ្រូគង្វាល និង ដែលបានបំពេញតាមលក្ខខ័ណ្ឌ ដូចដែលបានចែងទុក ។

ហេតុអ្វីបានជាមិនត្រូវឱ្យអ្នកទើបនឹងជឿថ្មីអធិប្បាយព្រះបន្ទូល ? ។

បើសិនជាមានបងប្អូនណាម្នាក់ធ្វើអំពើបាប ហើយមិនព្រមទទួលការប្រៀនប្រដៅ តើយើងត្រូវធ្វើដូចម្តេច ? ។

© Project WorldReach © SEAN

ជួយកែតម្រង់អ្នកធ្លាក់ចុះក្នុងសេចក្តីល្បួង

«បងប្អូនអើយ ប្រសិនបើមាននរណាម្នាក់ត្រូវគេទាន់ នៅពេលកំពុងតែធ្វើអំពើអាក្រក់ណាមួយ បងប្អូនដែលមានព្រះវិញ្ញាណនៅក្នុងខ្លួន ត្រូវកែតំរង់អ្នកនោះ ដោយចិត្តស្លូតបូត ។ ក៏ប៉ុន្តែ តោងប្រយ័ត្នខ្លួន ក្រែងលោអ្នកត្រូវធ្លាក់ក្នុងការល្បួងដូចគេដែរ » ។

(កាឡាទី ៦:១)

គ្រូគង្វាលល្អ មុខជាទុកចៀមស្មោះត្រង់ទាំង ៩៩ មួយឡែកសិនដើម្បីស្វែងរកចៀមមួយ ដែលវង្វេងបាត់ ។ ឃ្វាលបានន័យថា «ដឹកនាំ ការពារ ថែរក្សា និង អោយចំណីដល់ចៀម » ។ គ្រប់ហ្វូងចៀមតែងតែមានចៀមវង្វេងបាត់ ។



មិនចេះអួតបំពៅង

(មិនត្រូវមានឫកក្រអឺត)

គ្រូគង្វាលល្អ ត្រូវប្រុងប្រយ័ត្នកុំអោយអារក្សសាតាំងល្បួងគាត់អោយលើកតម្កើងខ្លួនឯង ។ បើសិនជាគ្រូគង្វាលមិនចេះទប់កុំឱ្យមានចរិតលក្ខណៈនេះ ដោយបន្ទាបខ្លួនទេនោះ គាត់នឹងក្លាយទៅជាមនុស្ស ដែលចេះតែស្តីបន្ទោសគេជាប់ជានិច្ច និង ជាអ្នកប្រើអំណាចផ្តាច់ការ ។ ព្រះជាម្ចាស់ធ្វើការតាមរយៈអ្នកបំរើ ដែលចេះបន្ទាបខ្លួន ។ គ្រូគង្វាលណាដែលចេះតែលើកតម្កើងខ្លួន និងដាក់បញ្ជា ប្រៀបដូចជាខ្លួនជាម្ចាស់លើក្រុមជំនុំ គាត់នឹងក្លាយទៅជាអ្នកដែលបំផ្លាញក្រុមជំនុំរបស់គាត់ ។ ព្រះយេស៊ូមិនដែលលើកតម្កើងព្រះអង្គទ្រង់ទេ ។ ព្រះអង្គទទួលក្មេងៗ លាងជើងអោយពួកសាវ័ក ព្រមទាំងសោយអាហារ និង ជជែកលេងជាមួយមនុស្សបាប និង អ្នកក្រខ្សត់ទៀតផង ។ ហើយទោះបីជាគេជេរប្រមាថព្រះអង្គយ៉ាងណាក៏ដោយ ក៏ព្រះអង្គមិនតបនឹងពួកគេវិញដែរ ។

តើហេតុអ្វីបានជាមារសាតាំងចេះតែវាយប្រហារយើង តាមរយៈការអួតបំពៅងរបស់យើង ? ។

© Project WorldReach © SEAN

មានកេរ្តិ៍ឈ្មោះល្អពីសំណាក់អស់អ្នក ដែលមិនមែនជាគ្រីស្តបរិស័ទ

មនុស្សមិនអាចមើលឃើញព្រះជាម្ចាស់ទេ តែអាចស្គាល់ព្រះជា-ម្ចាស់ តាមរយៈសេចក្តីស្រឡាញ់ ដែលផុសចេញពីចិត្ត និង ជីវិត របស់យើង ។ យើងស្រឡាញ់មនុស្សឯទៀត ដោយពាក្យសំដី និង ការប្រព្រឹត្តរបស់យើង (១ យ៉ូហាន ៤:១២, ១ យ៉ូហាន ៣:១៨) ។ គ្រូគង្វាលត្រូវមានកេរ្តិ៍ឈ្មោះល្អទាំងក្នុងក្រុមជំនុំ ទាំងក្នុងសហគមន៍ ។ គាត់ត្រូវជួយមនុស្សគ្រប់ពេល ដែលគាត់ អាចជួយបាន ។ គ្រូគង្វាលត្រូវចេះបង្កើតទំនាក់ទំនងជាមួយអ្នក ជឿ និង អ្នកមិនជឿ ។ ដូច្នេះ គ្រូគង្វាលមិនត្រូវឈ្លោះប្រកែក គ្នានៅក្នុងគ្រួសារទេ តែត្រូវបង្ហាញសេចក្តីស្រឡាញ់វិញ ។ គ្រូ គង្វាលត្រូវគោរពអ្នកដឹកនាំរដ្ឋអំណាចរបស់សហគមន៍ ។ គាត់ត្រូវ បង្ហាញសេចក្តីស្រឡាញ់ទាំងចំពោះអ្នកមាន ទាំងចំពោះអ្នកក្រ និង ចំពោះមនុស្សទាំងចាស់ ទាំងក្មេង ។ គ្រួសារណាដែលអាចបង្ហាញ សេចក្តីស្រឡាញ់ ព្រមទាំងអាចបង្ហាញទឹកចិត្តល្អ និង ទៀងត្រង់ នៅក្នុងសហគមន៍ តែងតែមានឱកាសផ្សព្វផ្សាយដំណឹងល្អ អំពី ព្រះយេស៊ូជានិច្ច ។

ដើម្បីបែងចែកភារៈកិច្ច ត្រូវសរសេរភារៈកិច្ចពិសេសៗ សំរាប់អ្នក បំពេញមុខងារបំរើម្នាក់ៗ ។ សមាជិកទាំងអស់គ្នាត្រូវដឹងពីមុខ-ងារបំរើរបស់ខ្លួន ។ យើងសូមជូនយោបល់ថា ត្រូវព្យួរបញ្ជីភារៈកិច្ច នេះ ទុកសំរាប់អោយសមាជិកមើល ។

អង្គការមួយអាចដំណើរការបានល្អ លុះត្រាតែសមាជិកម្នាក់ៗដឹង ពីភារៈកិច្ចរៀងៗខ្លួន ។

ហេតុអ្វីបានជាក្រុមជំនុំដែលកំពុងរីកចំរើន ត្រូវបែងចែកភារៈកិច្ច អោយពួកអ្នកចាស់ទុំ និង សមាជិកទាំងអស់ជួយបំពេញ ? ។

© Project WorldReach © SEAN

គ្រូគង្វាលដែលខ្សោយ ហើយមិនរឹងមាំ ខិតខំគ្រប់គ្រងអ្វីៗគ្រប់យ៉ាង ។ គាត់មិនអនុញ្ញាតិអោយអ្នកឯទៀតចូលរួមធ្វើការរៀបចំ និង ធ្វើការគ្រប់គ្រងក្រុមជំនុំទេ ។

គ្រូគង្វាលត្រូវចាត់ចែងការងារសំរាប់អ្នកចាស់ទុំ ឬ អ្នកដឹកនាំទាំងអស់ ដើម្បីអោយគេអាចបំពេញកិច្ចការបំរើរបស់ពួកគេរៀងៗខ្លួនបាន ។ ឯអ្នកចាស់ទុំម្នាក់ៗត្រូវជួយសមាជិកក្រុមរបស់ខ្លួនឱ្យអាចបំពេញកិច្ចការបំរើរបស់ពួកគេរៀងៗខ្លួន ស្របទៅតាមអំណោយទានខាងព្រលឹងវិញ្ញាណរបស់ពួកគេ ។

ជួនកាល ក្រុមជំនុំមួយស្ថិតនៅក្រោមការត្រួតត្រារបស់គ្រួសារមួយ ឬ សមាជិកចាស់ទុំមួយក្រុម ។ ធ្វើដូចនេះខុសហើយ ! គ្រូគង្វាល ត្រូវឱ្យសមាជិកចូលរួមចំណែកក្នុងការទទួលខុសត្រូវដែរ គឺរួមទាំងអ្នកជឿថ្មីផង ។ បើមិនដូច្នោះទេ ការងារនឹងនៅទ្រឹងមិនរីកចំរើនទៅមុខឡើយ ។ ដើម្បីការពារកុំអោយមានរឿងដូចខាងលើនេះ ត្រូវបង្រៀនអំពីអំណោយទាន ដែលព្រះជាម្ចាស់ប្រទានអោយអ្នកជឿទាំងអស់ (រ៉ូម ១២:១-៨, ១ កូរិនថូស ១២:១៣, អេភេសូ ៤:៧-១៦) ។ ជួយសមាជិកម្នាក់ៗឱ្យអាចដឹងពីអំណោយទាន និង បំពេញមុខងារបំរើរបស់ពួកគេផ្ទាល់ ដោយអំណោយទានទាំងនោះ ។

តើអ្នកអាចធ្វើដូចម្តេច ដើម្បីអោយពួកអ្នកមិនទាន់ជឿគោរពអ្នកកាន់តែខ្លាំង ? ។

© Project WorldReach © SEAN



គ្រូគង្វាលត្រូវណែនាំក្រុមជំនុំរបស់ខ្លួន ហើយជួយក្រុមជំនុំរៀបចំគោលដៅ និង ផែនការទុកជាមុន ដោយសំឡឹងមើលទៅពេលខាងមុខ ។ គាត់ត្រូវធ្វើជាគំរូ ដើម្បីជំរុញអោយក្រុមជំនុំរបស់គាត់បំពេញកិច្ចការ ដោយទឹកចិត្តពុះកញ្ជ្រោល និង អំណរ ។

គ្រូគង្វាលត្រូវសហការជាមួយអ្នកចាស់ទុំដទៃទៀតរបស់ក្រុមជំនុំ ។ បើសិនជាគ្រូគង្វាលម្នាក់ខិតខំត្រួតត្រាលើអ្វីៗគ្រប់យ៉ាង នោះការងាររបស់ក្រុមជំនុំនឹងចុះខ្សោយ ។ ពួកអ្នកចាស់ទុំត្រូវចូលរួមបំពេញភារៈកិច្ចឃ្វាលដែរ ។

បញ្ហាជាច្រើនក្នុងក្រុមជំនុំ កើតមានឡើងដោយសារគ្រូគង្វាលខ្លួនឯង ។ បើក្រុមជំនុំគ្មានការរៀបចំត្រឹមត្រូវទេ គ្រូគង្វាលនឹងក្លាយទៅជាអ្នកដែលខិតខំធ្វើអ្វីៗគ្រប់យ៉ាងដោយខ្លួនឯង ។



© Project WorldReach © SEAN

ណែនាំប្រមូលសមាជិកទាំងអស់អោយ
បំពេញកិច្ចការបំរើរបស់ពួកគេ

«គឺព្រះអង្គហើយ ដែលបានប្រទានអោយអ្នកខ្លះ មានមុខងារជា គ្រីស្តទូត អោយអ្នកខ្លះថ្លែងព្រះបន្ទូល អ្នកខ្លះផ្សាយដំណឹងល្អ អ្នកខ្លះជាអ្នកគង្វាល និង អ្នកខ្លះទៀតជាអ្នកបង្រៀន ដើម្បីរៀបចំប្រជាជនដ៏វិសុទ្ធអោយបំពេញមុខងារបំរើ និង កសាងព្រះកាយរបស់ព្រះគ្រីស្តឡើង » ។

(អេភេសូ ៤:១១-១២)

យោងទៅតាមវគ្គគម្ពីរខាងលើ តើ « គ្រូគង្វាល និង គ្រូបង្រៀន » ត្រូវបង្ហាត់បង្រៀនអ្នកណា ? ។

តើគ្រូគង្វាល និង គ្រូបង្រៀនត្រូវបង្ហាត់បង្រៀនអ្នកជឿក្នុងគោលបំណងដូចម្តេច ? ។

មុខងារបំរើទាំងអស់ មិនមែនគ្រាន់តែសំរាប់គ្រូគង្វាល និង គ្រូបង្រៀនប៉ុណ្ណោះទេ ប៉ុន្តែ សំរាប់ប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងអស់ ។

ផ្នែក ទី ២

ភារៈកិច្ចរបស់គ្រូគង្វាល គឺអធិប្បាយព្រះបន្ទូល

«ខ្ញុំសុំបញ្ជាក់យ៉ាងម៉ឺងម៉ាត់ នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ និង នៅចំពោះព្រះភ័ក្ត្រព្រះគ្រីស្តយេស៊ូ ដែលនឹងវិនិច្ឆ័យទោសទាំងមនុស្សរស់ ទាំងមនុស្សស្លាប់ ហើយខ្ញុំសូមបញ្ជាក់ក្នុងព្រះនាមព្រះអង្គ ដែលយាងមកយ៉ាងឱឡារឹក ដើម្បីគ្រងរាជ្យនោះថា ចូរប្រកាសព្រះបន្ទូល ព្រមទាំងនិយាយហើយនិយាយទៀត ទោះមានឱកាសល្អក្តី មិនល្អក្តី ត្រូវពន្យល់គេអោយដឹងខុសត្រូវ ស្តីបន្ទោស ដាស់តឿន និង បង្រៀនគេ ដោយចិត្តអត់ធ្មត់គ្រប់ជំពូក »

(២ ធីម៉ូថេ ៤:១-២)

ដើម្បីអាចអធិប្បាយឱ្យបានល្អ ត្រូវសិក្សាព្រះគម្ពីរជាបន្តរហូត ។ ត្រូវខិតខំស្វែងរកសេចក្តីក្នុងព្រះគម្ពីរ ដែលជួយកសាងក្រុមជំនុំរបស់អ្នក ។ ពេលអធិប្បាយ ត្រូវផ្តាស់ប្តូរប្រធានបទ ។ ត្រូវអធិប្បាយឱ្យទាក់ទងទៅនឹងសេចក្តីត្រូវការរបស់ក្រុមជំនុំ ដោយមិនស្តីបន្ទោសគេម្តងហើយម្តងទៀត តែត្រូវនិយាយផ្ទាល់ជាមួយ

អ្នក ដែលត្រូវទទួលដំបូន្មាន ។ បើអ្នកឈប់សិក្សាព្រះបន្ទូល អ្នកក៏ត្រូវឈប់អធិប្បាយព្រះបន្ទូលដែរ ។ ត្រូវអធិប្បាយខ្លីល្មម ។ សេចក្តីអធិប្បាយដែលខ្លីល្មម តែរៀបចំល្អមានប្រយោជន៍ជាង សេចក្តីអធិប្បាយវែង ដែលមិនបានរៀបចំអោយបានត្រឹមត្រូវ ។

ផ្តល់ដំបូន្មានដល់ពួកអ្នកឈឺ

«ត្រូវមានចិត្តស្លូតបូត ប្រដៅពួកអ្នកប្រឆាំង ក្រែងលោព្រះជា-ម្ចាស់នឹងប្រោសប្រទានអោយគេកែប្រែចិត្តគំនិត ដើម្បីអោយគេបានស្គាល់សេចក្តីពិតយ៉ាងច្បាស់ » ។

(២ ធីម៉ូថេ ២:២៥)

យើងផ្តល់ដំបូន្មាន ដោយផ្ទាល់ :

- ចំពោះអ្នកដែលជិតរៀបការ ។
- ចំពោះប្តីប្រពន្ធដែលមានបញ្ហារវាងគ្នា និង គ្នា ។
- ចំពោះអ្នកដែលកំពុងកាន់មរណៈទុក្ខ ។
- ចំពោះអ្នកជំងឺ ។

ផ្សព្វផ្សាយដំណឹងល្អអំពីព្រះគ្រីស្ត

«... ត្រូវបំពេញកិច្ចការជាអ្នកផ្សព្វផ្សាយដំណឹងល្អ ព្រមទាំងបំពេញមុខងាររបស់ខ្លួន អោយបានល្អប្រសើរផង » (២ ធីម៉ូថេ ៤:៥) ។ គ្រូគង្វាលក៏ជាអ្នកផ្សាយដំណឹងល្អអំពីព្រះយេស៊ូដែរ ។



«ប្រកាស »ដំណឹងល្អ មិនមែនគ្រាន់តែនិយាយនៅមុខមនុស្សច្រើនទេ ។ អ្នកអាច «ប្រកាស » ដំណឹងល្អ ពេលអង្គុយពិសាការហូរួមតុជាមួយមិត្តភក្តិ ឬក៏អាច «ប្រកាស »ដំណឹងល្អ តាមរយៈការសំដែងឆាកល្ខោន និង តាមរបៀបផ្សេងៗច្រើនទៀតដែរ ។

នៅពេលដែលអ្នកទៅសួរសុខទុក្ខមនុស្ស ដើម្បីផ្សាយដំណឹងល្អដល់គេ សូមនាំអ្នកឯទៀតទៅជាមួយអ្នក ដើម្បីអោយអ្នកទាំងនោះចេះពីរបៀបផ្សាយដំណឹងល្អដែរ ។

ហើយមិនព្រមកែខ្លួន នោះគ្រូគង្វាល និង អ្នកចាស់ទុំត្រូវប្រៀនប្រដៅគាត់ ។ បើសិនជាអ្នកនោះមិនយកចិត្តទុកដាក់ស្តាប់គ្រូគង្វាល មិនស្តាប់អ្នកចាស់ទុំ និង មិនស្តាប់ក្រុមជំនុំ នោះមិនត្រូវឱ្យគាត់ចូលរួមធ្វើពិធីកាច់នំបុ័ងទេ (ម៉ាថាយ ១៨:១៥-១៨, ១ កូរិនថូស ៥:១១) ។

បើគាត់មិនស្តាប់អ្នកដឹកនាំ ឬ ក្រុមជំនុំ ហើយនៅតែប្រព្រឹត្តអំពើខុសឆ្គងនោះ ១ កូរិនថូស ជំពូក ៥ តម្រូវអោយយើងផ្តាច់ការទាក់ទងជាមួយគាត់ រហូតដល់គាត់កែប្រែចិត្តគំនិត ។ នៅក្នុងវគ្គគម្ពីរនេះ លោកប៉ូលកែតម្រង់ដោយមិនដាក់ទោសទេ ។ ដូចគ្នានេះដែរ យើងត្រូវកែតម្រង់អ្នកធ្វើខុស ដោយចិត្តស្លូតបូត និង ប្រយ័ត្នខ្លួន ក្រែងលោត្រូវធ្លាក់ក្នុងការល្បួងដូចគេដែរ (កាឡាទី ៦:១) ។ យើងមិនត្រូវទាមទារឱ្យអ្នកជឿថ្មីបានគ្រប់លក្ខណៈភ្លាមៗ នោះទេ ។

សូមសរសេរជំហានទាំងបីខាងក្រោមនេះ ដែលសំរាប់ប្រៀនប្រដៅបងប្អូនដែលធ្វើខុស ស្របទៅតាម ម៉ាថាយ ១៨:១៥-១៨, កាឡាទី ៦:១, ១ ធីម៉ូថេ ៥:១៩ :

- ចំពោះអ្នកដែលធ្លាក់ចុះក្នុងអំពើបាប (គឺអ្នកដែលបែរចេញពីព្រះជាម្ចាស់) ។
- ចំពោះអ្នកជឿស្មោះត្រង់ ដើម្បីអញ្ជើញពួកគេអោយបំពេញភារៈកិច្ចក្នុងក្រុមជំនុំ ។
- ចំពោះអ្នកដែលចង់អោយជាពីរបួសខាងផ្លូវចិត្ត ដោយសារមានការបាក់បែកគ្នា ឬ មានអំពើបាបដែលលាក់ជ្រៅនៅក្នុងចិត្ត ។
- ចំពោះអ្នកដែលមានបញ្ហាខាងផ្លូវចិត្ត ឬ អ្នកដែលប្រាសចាកសីលធម៌ ។

ត្រូវជួយអ្នកជឿអោយអាចយល់ពីបញ្ហាផ្ទាល់ខ្លួនរបស់គេ ។ ត្រូវស្តាប់អ្នកនោះនិយាយសិន មុននឹងនិយាយខ្លួនឯង ។ មនុស្សមានបញ្ហា ច្រើនតែបានធូរស្រាល ដោយគ្រាន់តែអាចនិយាយពីបញ្ហារបស់ខ្លួន និង ចាប់ផ្តើមពិនិត្យមើលបញ្ហានេះថែមទៀត តាមការពិតជាក់ស្តែង ។

© Project WorldReach © SEAN

ត្រូវអោយអ្នកចាស់ទុំស្ត្រីទៅសួរសុខទុក្ខស្ត្រីដូចគ្នា ។



ដើម្បីអាចចេះជួយផ្តល់ដំបូន្មានកាន់តែច្រើនដល់ក៏វិតនេះ ត្រូវសុំអោយគ្រូបង្ហាត់របស់អ្នកផ្តល់ការសិក្សាថែមទៀត ដែលស្តីអំពីកិច្ចការឃ្វាល និង ការផ្តល់ដំបូន្មាន ។

ធ្វើពិធីកាច់នំបុ័ង និង ប្រែ្រនប្រដៅជាប់ជានិច្ច

«*...ចូរធ្វើដូច្នេះ ដើម្បីរំឭកដល់ខ្ញុំ*» (១ កូរិនថូស ១១:២៤) ។

យើងធ្វើពិធីកាច់នំបុ័ង រួមជាមួយអ្នកជឿដែលបានទទួលពិធីជ្រមុជទឹក និង បានកែប្រែចិត្តគំនិតពីអំពើបាប ។ ក្រុមជំនុំខ្លះ ធ្វើពិធីកាច់នំបុ័ងរាល់អាទិត្យ ក្រុមជំនុំខ្លះទៀតធ្វើរាល់ខែ ។

ពិធីកាច់នំបុ័ងរំលឹកពីសម្ពន្ធមេត្រីថ្មីរបស់ព្រះយេស៊ូគ្រីស្ត ។ ពិធីកាច់នំបុ័ងរំលឹកយើងពីការសុគតរបស់ព្រះយេស៊ូគ្រីស្ត ដើម្បីប្រោសលោះយើង និង ពីការយាងមកជាលើកទីពីររបស់ព្រះអង្គ ។ ពិធីនេះ ជាឱកាសមួយសំខាន់ណាស់ ។ នៅពេលដែលយើងធ្វើពិធីកាច់នំបុ័ង គឺយើងបានរួមជាមួយព្រះអម្ចាស់របស់យើង និង ប្រជារាស្ត្ររបស់ព្រះអង្គ ។

មុននឹងចូលរួមកាច់នំបុ័ង អ្នកជឿត្រូវពិនិត្យពិច័យមើលចិត្តគំនិតខ្លួនឯងសិន ហើយអធិស្ឋានក្នុងចិត្តលន់តួសារភាពអំពើបាបរបស់ខ្លួន (១ កូរិនថូស ១១:២៧-៣២) ។ ព្រះជាម្ចាស់លើកលែងទោសអំពើបាបរបស់យើង ប៉ុន្តែ ព្រះអង្គចង់ឱ្យយើងទទួលស្គាល់កំហុសរបស់យើង និង កែប្រែការប្រព្រឹត្តរបស់យើង (១ យ៉ូហាន ១:៨-១០) ។ បើសិនជាបងប្អូនណាម្នាក់ធ្លាក់ចុះក្នុងសេចក្តីល្បួង